# មាតិកា

## I- ខុទ្ទកាល័យព្រះមហាក្សត្រ

### ១-ព្រះរាជក្រឹត្យ


| | | |
|---|---|---|
| ១៣-៣-២០០០ | -ព្រះរាជក្រឹត្យ ជស/រកត/០៣០០/១១៩ តែងតាំងឯកឧត្តម ម៉ុល លឹម ជាប្រធានក្រុមប្រឹក្សាអ្នកច្បាប់របស់ក្រសួងមហាផ្ទៃ | ៤៦៩ |
| ០៩-៣-២០០០ | -ព្រះរាជក្រឹត្យលេខ ជស/រកត/០៣០០/១២០ តំលើងឋានន្តរសក្តិថ្នាក់ឧត្តមសេនីយទោ ជាកិត្តមរណសព្ទ ជូនចំពោះសព ឧត្តមសេនីយត្រី ខៀវ និត , នូវជ័យវិក្រិ | ៤៧០ |
| ០៩-៣-២០០០ | -ព្រះរាជក្រឹត្យ ជស/រកត/០៣០០/១២១ តំលើងឋានៈលោក គឹម ម៉ុនថាន នាយករងខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី | ៤៧១ |
| ០៩-៣-២០០០ | -ព្រះរាជក្រឹត្យ ជស/រកត/០៣០០/១២២ តំលើងឋានន្តរសក្តិថ្នាក់ឧត្តមសេនីយទោ ជូនឧត្តមសេនីយត្រី ប្រាក់ ទណ្ណឌី | ៤៧២ |
| ០៩-៣-២០០០ | -ព្រះរាជក្រឹត្យ ជស/រកត/០៣០០/១២៤ តំលើងឋានន្តរសក្តិ ថ្នាក់ឧត្តមសេនីយត្រី ជូនវរសេនីយឯក លឹម លាងសែ | ៤៧៣ |


## II- រាជរដ្ឋាភិបាល

### ១- អនុក្រឹត្យ


| | | |
|---|---|---|
| ១៥-៣-២០០០ | -អនុក្រឹត្យ លេខ ១០ អនក្រ.បក ស្តីពីការប្តូរឈ្មោះគ្រុកម្មករក់នួន នៃខេត្តបាត់ដំបង | ៤៧៤ |
| ០៩-៣-២០០០ | -អនុក្រឹត្យ លេខ ៩៣ អនក្រ.គត ស្តីពីការដាក់មន្ត្រីរាជការឲ្យចូលនិវត្តន៍ | ៤៧៥ |
| ១៣-៣-២០០០ | -អនុក្រឹត្យ លេខ ៩៤ អនក្រ.គត ស្តីពីការតែងតាំងមន្ត្រីរាជការ | ៤៧៦ |
| ១៤-៣-២០០០ | -អនុក្រឹត្យ លេខ ៩៥ អនក្រ.គត ស្តីពីការតែងតាំងមន្ត្រីរាជការ | ៤៧៧ |
| ១៤-៣-២០០០ | -អនុក្រឹត្យ លេខ ៩៦ អនក្រ.គត ស្តីពីការបំពាក់ឋានន្តរសក្តិនាយនគរបាលជាតិ | ៤៧៨ |
| ១៥-៣-២០០០ | -អនុក្រឹត្យ លេខ ៩៧ អនក្រ.គត ស្តីពីការបំពាក់ឋានន្តរសក្តិនាយទាហាននៃកងយោធពលខេមរភូមិន្ទ | ៤៧៩ |
| ១៥-៣-២០០០ | -អនុក្រឹត្យ លេខ ៩៨ អនក្រ.គត ស្តីពីការជូនមេដាយស្ថាបនាជាតិ | ៤៨០ |
| ១៥-៣-២០០០ | -អនុក្រឹត្យ លេខ ៩៩ អនក្រ.គត ស្តីពីការជូនមេដាយស្ថាបនាជាតិ | ៤៨១ |
| ១៥-៣-២០០០ | -អនុក្រឹត្យ លេខ ១០០ អនក្រ.គត ស្តីពីការជូនមេដាយស្ថាបនាជាតិ | ៤៨២ |

| | | |
|---|---|---|
| ១៥-៣-២០០០ | -អនុក្រឹត្យ លេខ ១០១ អនក្រ.តត ស្ដីពីការផ្ដល់មេដាយ ស្ថាបនាជាតិ | ៤៨៣ |
| ១៥-៣-២០០០ | -អនុក្រឹត្យ លេខ ១០២ អនក្រ.តត ស្ដីពីការផ្ដល់មេដាយ ស្ថាបនាជាតិ | ៤៨៥ |
| ១៥-៣-២០០០ | -អនុក្រឹត្យ លេខ ១០៣ អនក្រ.តត ស្ដីពីការផ្ដល់មេដាយ ស្ថាបនាជាតិ | ៤៨៥ |
| ១៥-៣-២០០០ | -អនុក្រឹត្យ លេខ ១០៤ អនក្រ.តត ស្ដីពីការផ្ដល់មេដាយ ស្ថាបនាជាតិ | ៤៨៦ |
| ១៥-៣-២០០០ | -អនុក្រឹត្យ លេខ ១០៥ អនក្រ.តត ស្ដីពីការផ្ដល់មេដាយ ស្ថាបនាជាតិ | ៤៨៧ |
| ១៥-៣-២០០០ | -អនុក្រឹត្យ លេខ ១០៦ អនក្រ.តត ស្ដីពីការផ្ដល់មេដាយ ស្ថាបនាជាតិ | ៤៨៨ |

២-សេចក្ដីសំរេច

| | | |
|---|---|---|
| ០៩-៣-២០០០ | -DECISION N 15D. The appointment of an Advisor to the Prime Minister of the Kingdom of Cambodia | 489 |
| ១៥-៣-២០០០ | -សេចក្ដីសំរេច លេខ ១៦ សសរ ស្ដីពីរូបសញ្ញាក្រសួងការពារជាតិ | ៤៩០ |

III-ការងារបណ្ដាក្រសួង

១-នីស្ដីការគណៈរដ្ឋមន្ត្រី

សេចក្ដីសំរេច

| | | |
|---|---|---|
| ១៣-៣-២០០០ | -សេចក្ដីសំរេច លេខ ២០ សសរ. ស្ដីពីការចាត់ការកិច្ចមន្ត្រីមធ្យមជំនាន់សន្តិភាព ២ | ៤៩១ |
| ១៣-៣-២០០០ | -សេចក្ដីសំរេច លេខ ២១ សសរ. ស្ដីពីការជ្រើសរើសកន្លែងបំពេញមុខងាររបស់សិស្ស មន្ត្រីមធ្យមជំនាន់សន្តិភាព ២ | ៤៩២ |

២-នីស្ដីការរដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល

ប្រកាស

| | | |
|---|---|---|
| ១៣-៣-២០០០ | -ប្រកាស លេខ ១៥១ កឧ.ប្រក អនុញ្ញាតឲ្យក្រុមហ៊ុន ភ្នំពេញ ធើរបែកខូ (ខេមបូឌា) តំណាងដោយលោក វិញហួរ សញ្ជាតិកម្ពុជា បង្កើតរោងចក្រផលិតបារី សំរាប់នាំចេញ | ៤៩៤ |

៣-នីស្ដីការរដ្ឋមន្ត្រី ក្រសួងអប់រំ យុវជន និងកីឡា

ប្រកាស

| | | |
|---|---|---|
| ១៥-៣-២០០០ | -ប្រកាស លេខ ៥៦៩ អយក.ប្រក ស្ដីពីការបើកអនុវិទ្យាល័យ ទួលក្បិល ក្នុងឃុំកំពង់ស្វាយ ស្រុកកំពង់ស្វាយ ខេត្ត កំពង់ធំ | ៤៩៥ |

៤-នីស្ដីការរដ្ឋមន្ត្រី ក្រសួងប៉ុស្តិ៍ទូរគមនាគមន៍ និង ទូរគមនាគមន៍

ប្រកាស

| | | |
|---|---|---|
| ១០-៣-២០០០ | -ប្រកាស លេខ ០៤៦ បទ.ប្រក ស្ដីពីការបង្កើតការិយាល័យវិទ្យុឆ្នេរសមុទ្រ | ៤៩៧ |

# I- ខុទ្ទកាល័យព្រះមហាក្សត្រ

## ព្រះរាជក្រឹត្យ

### ព្រះរាជក្រឹត្យលេខ នស/រកត/០៣០០/១១៩

**យើង**

**ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ**

**រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍**

**និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ**

**ព្រះចៅក្រុងកម្ពុជាធិបតី**

***

- បានទ្រង់យល់ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ : នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំង រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដាឆ្នាំ ១៩៩៤ ដែល ប្រកាសឲ្យប្រើច្បាប់ ស្តីពីការរៀបចំនិងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- យោងតាមសំណើរបស់នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០៦ ខែ មីនា ឆ្នាំ ២០០០

**ត្រាស់បង្គាប់**

មាត្រា ១.- តែងតាំងឯកឧត្តម ម៉ុល ឈឹម ជាប្រធានក្រុមអ្នកច្បាប់របស់ក្រសួងមហាផ្ទៃ ដោយមានឋានៈ និងបុព្វសិទ្ធិស្មើនឹង អនុរដ្ឋលេខាធិការ បន្ថែមលើមុខងារបច្ចុប្បន្ន ។

មាត្រា ២.- នាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវអនុវត្តឲ្យបានសំរេចនូវព្រះរាជក្រឹត្យនេះ ។

មាត្រា ៣.- ព្រះរាជក្រឹត្យនេះ ចូលជាធរមានចាប់ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ១៣ ខែ មីនា ឆ្នាំ ២០០០

ក្នុងព្រះបរមនាម និងតាមព្រះរាជត្រាស់បង្គាប់

ប្រមុខរដ្ឋស្តីទី

ហត្ថលេខា

ជា ស៊ីម

★★★

# ព្រះរាជក្រឹត្យលេខ នស/រកត/០៣០០/១២០

**យើង**

**ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ**

**រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍**

**និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ**

**ព្រះចៅក្រុងកម្ពុជាធិបតី**

***

- បានទ្រង់ឃើញ រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់ឃើញ ព្រះរាជក្រឹត្យលេខនស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់ឃើញ ព្រះរាជក្រម លេខនស/រកម/៩៤/០២ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់ឃើញ ព្រះរាជក្រម លេខនស/រកម/០១៩៦/០៧ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើត ក្រសួងមហាផ្ទៃ
- បានទ្រង់ឃើញ ព្រះរាជក្រឹត្យ លេខនស/រកត/០១៩៩/២១ ចុះថ្ងៃ ២៤ ខែ មករា ឆ្នាំ ១៩៩៩ ស្តីពីការកែសម្រួលតួនាទីភារកិច្ចនិងរចនាសម្ព័ន្ធចាត់តាំងអគ្គបញ្ជាការដ្ឋាន នៃកងយោធពលខេមរភូមិន្ទ
- បានទ្រង់ឃើញសំណើរបស់សហរដ្ឋមន្ត្រីក្រសួងការពារជាតិ និងនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា

**មាត្រា ១.-** ត្រូវបានតម្លើងឋានន្តរស័ក្តិ ថ្នាក់ឧត្តមសេនីយ៍ទោ ជាកិច្ចបច្ឆាមរណៈជូនចំពោះសព :

១- ឧត្តមសេនីយ៍ត្រី **ខៀវ និន** អត្តលេខ ០០០២៨៣ នាយករិយាល័យទី៥ បញ្ជាការ ដ្ឋានកងទ័ពជើងគោក

២- ឧត្តមសេនីយ៍ត្រី **នួន ជ័យឫទ្ធិ** អត្តលេខ ០០០១២២ មេបញ្ជាការរង យោធភូមិភាគទី ៣

**មាត្រា ២.-** នាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវអនុវត្តឲ្យបានសម្រេចនូវព្រះរាជក្រឹត្យនេះ ។

**មាត្រា ៣.-** ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ០៩ ខែ មីនា ឆ្នាំ ២០០០

ក្នុងព្រះបរមនាម និងតាមព្រះរាជក្រាស់បង្គាប់

ប្រមុខរដ្ឋស្តីទី

ហត្ថលេខា

**ជា ស៊ីម**

## ព្រះរាជក្រឹត្យលេខ ជស/រកត/០៣០០/១២១

**យើង**

**ព្រះបាទសម្ដេចព្រះ នរោត្ដម សីហនុ**

**រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍**

**និករោត្ដម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ**

**ព្រះចៅក្រុងកម្ពុជាធិបតី**

***

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស / រកត / ១១៩៨ / ៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស / រកម / ៩៤ / ០២ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្ដីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់អនុក្រឹត្យលេខ ៧៦ / អនក្រ / បក/ ចុះថ្ងៃទី ០១ ខែ ធ្នូ ឆ្នាំ ១៩៩៨ ស្ដីពីការរៀបចំ និងប្រព្រឹត្តទៅនៃខុទ្ទកាល័យរបស់សម្ដេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា
- យោងតាមសំណើរបស់នាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ចុះថ្ងៃទី ០១ ខែ មីនា ឆ្នាំ ២០០០

**ត្រាស់បង្គាប់**

**មាត្រា ១.-** ត្រូវបានតម្លើងឋានៈលោក **គឹម ប៊ុនថាន** នាយករងខុទ្ទកាល័យសម្ដេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាល កម្ពុជា មានឋានៈស្មើ អគ្គនាយក ។

**មាត្រា ២.-** នាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវអនុវត្តឲ្យបានសម្រេច នូវព្រះរាជក្រឹត្យនេះ ។

**មាត្រា ៣.-** ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្ថលេខានេះតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ០៩ ខែ មីនា ឆ្នាំ ២០០០

ក្នុងព្រះបរមនាម និងតាមព្រះរាជត្រាស់បង្គាប់

ប្រមុខរដ្ឋស្ដីទី

ហត្ថលេខា

ជា ស៊ីម

★★★

# ព្រះរាជក្រឹត្យលេខ នស/រកត/០៣០០/១២២

**យើង**

**ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ**

**រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍**

**និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ**

**ព្រះចៅក្រុងកម្ពុជាធិបតី**

***

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស / រកត / ១១៩៨ / ៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស / រកម / ៩៤ / ០២ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៧ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើត ក្រសួងការពារជាតិ
- យោងតាមសំណើរបស់នាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ចុះថ្ងៃទី ០៦ ខែ មីនា ឆ្នាំ ២០០០

**ត្រាស់បង្គាប់**

**មាត្រា ១.-** ត្រូវបានតម្លើងឋានន្តរសក្តិ **ថ្នាក់ឧត្តមសេនីយ៍ទោ** កងយោធពលខេមរភូមិន្ទ នៃអគ្គបញ្ជាការដ្ឋាន ជូនឧត្តមសេនីយ៍ត្រី **ប្រាក់ វណ្ណឌី** អត្តលេខ ០០០១៧៧ បច្ចុប្បន្ន នាយករងខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ។

**មាត្រា ២.-** នាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវអនុវត្តឲ្យបានសម្រេច នូវព្រះរាជក្រឹត្យនេះ ។

**មាត្រា ៣.-** ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ០៩ ខែ មីនា ឆ្នាំ ២០០០

ក្នុងព្រះបរមនាម និងតាមព្រះរាជគ្រាស់បង្គាប់

ប្រមុខរដ្ឋស្តីទី

ហត្ថលេខា

**ជា ស៊ីម**

★★★

# ព្រះរាជក្រឹត្យលេខ ជស/រកត/០៣០០/១២៤

យើង

ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ

រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍

និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ

ព្រះចៅក្រុងកម្ពុជាធិបតី

***

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស / រកត / ១១៩៨ / ៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស / រកម / ៩៤ / ០២ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៧ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើត ក្រសួងការពារជាតិ
- យោងតាមសំណើរបស់នាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ចុះថ្ងៃទី ០៧ ខែ មីនា ឆ្នាំ ២០០០

ត្រាស់បង្គាប់

មាត្រា ១.- ត្រូវបានតម្លើងឋានន្តរសក្តិ **ថ្នាក់ឧត្តមសេនីយ៍ត្រី** កងយោធពលខេមរភូមិន្ទ នៃអគ្គបញ្ជាការដ្ឋាន ជូនវរសេនីយ៍ឯក **លឹម លាងសែ** អត្តលេខ ០០១១៦៩ បច្ចុប្បន្ន ជំនួយការសម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ។

មាត្រា ២.- នាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវអនុវត្តឲ្យបានសំរេច នូវព្រះរាជក្រឹត្យនេះ ។

មាត្រា ៣.- ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្ថលេខានេះតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ០៩ ខែ មីនា ឆ្នាំ ២០០០

ក្នុងព្រះបរមនាម និងតាមព្រះរាជត្រាស់បង្គាប់

ប្រមុខរដ្ឋស្តីទី

ហត្ថលេខា

**ជា ស៊ីម**

★★★

# II- រាជរដ្ឋាភិបាល

## ១. អនុក្រឹត្យ

### អនុក្រឹត្យលេខ ១០ អនក្រ .បក

### ស្តីពីការប្តូរឈ្មោះស្រុកមួយចំនួន នៃខេត្តបាត់ដំបង

***

**រាជរដ្ឋាភិបាល**

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- តាមសំណើរបស់សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

**សំរេច**

មាត្រា ១.- ត្រូវបានប្តូរឈ្មោះស្រុកបាត់ដំបង បច្ចុប្បន្នចំណុះខេត្តបាត់ដំបង មកជាស្រុកថ្មគោល ចំណុះខេត្តបាត់ដំបង ។

មាត្រា ២.- ទីតាំងរដ្ឋបាលសាលាស្រុកថ្មគោល ស្ថិតនៅក្នុងឃុំតាពូង ។

មាត្រា ៣.- ត្រូវបានប្តូរឈ្មោះស្រុកស្វាយប៉ោ បច្ចុប្បន្នចំណុះខេត្តបាត់ដំបង មកជាស្រុកបាត់ដំបង ចំណុះខេត្តបាត់ដំបង ។

មាត្រា ៤.- ទីតាំងរដ្ឋបាលសាលាស្រុកបាត់ដំបង ស្ថិតនៅក្នុងឃុំស្វាយប៉ោ ។

មាត្រា ៥.- បទបញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា ៦.-** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង គ្រប់រដ្ឋលេខាធិការដ្ឋាន និងអភិបាលខេត្តបាត់ដំបង មានភារកិច្ចអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ១៤ ខែ មីនា ឆ្នាំ ២០០០

នាយករដ្ឋមន្ត្រី

ហត្ថលេខា និង ត្រា

**ហ៊ុន សែន**

★★★

**អនុក្រឹត្យលេខ ៩៣ អនក្រ.តត**

**ស្តីពីការដាក់មន្ត្រីរាជការឲ្យចូលនិវត្តន៍**

***

**រាជរដ្ឋាភិបាល**

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ២៦ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល
- បានឃើញអនុក្រឹត្យលេខ ៤០ អនក្រ.បក ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ១៩៩៦ ស្តីពីការកំណត់លក្ខណៈវិនិច្ឆ័យមន្ត្រីរាជការស៊ីវិល ដែលស្នើសុំពន្យារពេលចូលនិវត្តន៍
- យោងតាមសំណើរបស់ក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ

**សំរេច**

**មាត្រា ១.-** ត្រូវបានអនុញ្ញាតឲ្យឯកឧត្តម **កែម មន្តល** កើតថ្ងៃទី ១០ ខែ កុម្ភៈ ឆ្នាំ ១៩៤៥ បច្ចុប្បន្ន ឯកអគ្គរាជទូតនៃព្រះរាជាណាចក្រកម្ពុជាប្រចាំសាធារណរដ្ឋសឹង្ហបុរី ចូលនិវត្តន៍ក្នុងតំណែងមុខងារសាធារណៈ ដោយទុកឲ្យសាមីខ្លួននៅបន្តបេសកកម្មជាឯកអគ្គរាជទូត រហូតដល់ចប់អាណត្តិ ។

**មាត្រា ២.-** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការបរទេស និង សហប្រតិបត្តិការអន្តរជាតិ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ សហរដ្ឋមន្ត្រី

រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួងស្ថាប័នដែលពាក់ព័ន្ធ និង សាមីខ្លួន ត្រូវអនុវត្តអនុក្រឹត្យនេះឲ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ០៩ ខែ មីនា ឆ្នាំ ២០០០

នាយករដ្ឋមន្ត្រី

ហត្ថលេខា និង ត្រា

**ហ៊ុន សែន**

★★★

## អនុក្រឹត្យលេខ ៩៤ អនក្រ .តត

## ស្តីពីការតែងតាំងមន្ត្រីរាជការ

***

## រាជរដ្ឋាភិបាលកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ នស / រកត / ០៣៩៩ / ៧២ ចុះថ្ងៃទី ១៩ ខែ មីនា ឆ្នាំ ១៩៩៩ ស្តីពីការបង្កើតឧត្តមក្រុមប្រឹក្សាកំណែទំរង់រដ្ឋបាល
- បានឃើញអនុក្រឹត្យលេខ ៤១ អនក្រ.បក ចុះថ្ងៃទី ១២ ខែ ឧសភា ឆ្នាំ ១៩៩៩ ស្តីពីការបង្កើតក្រុមរំសាយកងកំលាំងប្រដាប់អាវុធ
- បានឃើញអនុក្រឹត្យលេខ ៤៣ អនក្រ.បក ចុះថ្ងៃទី ១២ ខែ ឧសភា ឆ្នាំ ១៩៩៩ ស្តីពីការបង្កើតក្រុមប្រឹក្សារំសាយកងកំលាំងប្រដាប់អាវុធ
- បានឃើញអនុក្រឹត្យលេខ ៤២ អនក្រ.បក ចុះថ្ងៃទី ១២ ខែ ឧសភា ឆ្នាំ ១៩៩៩ ស្តីពីការបង្កើតអគ្គលេខាធិការដ្ឋាន នៃក្រុមប្រឹក្សារំសាយកងកំលាំងប្រដាប់អាវុធ

## សំរេច

**មាត្រា ១.-** តែងតាំង លោក ម៉ុន ធារី ជាអគ្គលេខាធិការរង របស់អគ្គលេខាធិការដ្ឋាននៃក្រុមប្រឹក្សារំសាយកងកំលាំងប្រដាប់អាវុធ បន្ថែមលើមុខងារបច្ចុប្បន្ន ។

មាត្រា ២.- ទេសរដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួងស្ថាប័ន ពាក់ព័ន្ធ សមាជិកទាំងអស់ នៃក្រុមប្រឹក្សារំសាយពងក់លាំងប្រដាប់អាវុធ និងសាមីខ្លួនត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះឲ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ១៣ ខែ មីនា ឆ្នាំ ២០០០

នាយករដ្ឋមន្ត្រី

ហត្ថលេខា និង ត្រា

**ហ៊ុន សែន**

★★★

## អនុក្រឹត្យលេខ ៩៥ អនក្រ .តត

## ស្ដីពីការតែងតាំងមន្ត្រីរាជការ

***

## រាជរដ្ឋាភិបាលកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ ស្ដីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ០៣ / ៩៩ / ៧២ ចុះថ្ងៃទី ១៨ ខែ មីនា ឆ្នាំ ១៩៩៩ ស្ដីពីការបង្កើតឧត្តមក្រុមប្រឹក្សាកំណែទម្រង់រដ្ឋ
- បានឃើញអនុក្រឹត្យលេខ ៥១ អនក្រ.បក ចុះថ្ងៃទី ១០ ខែ មិថុនា ឆ្នាំ ១៩៩៩ ស្ដីពីការបង្កើតក្រុមប្រឹក្សាកំណែទំរង់រដ្ឋបាល
- បានឃើញអនុក្រឹត្យលេខ ៥២ អនក្រ.បក ចុះថ្ងៃទី ១០ ខែ មិថុនា ឆ្នាំ ១៩៩៩ ស្ដីពីការរៀបចំ និងការប្រព្រឹត្តិទៅរបស់អគ្គលេខាធិការដ្ឋាន នៃក្រុមប្រឹក្សាកំណែទំរង់រដ្ឋបាល
- តាមសំណើររបស់ប្រធានក្រុមប្រឹក្សា កំណែទំរង់រដ្ឋបាល

## សំរេច

មាត្រា ១.- តែងតាំងលោក ម៉ុល តីឌូ ជាអគ្គលេខាធិការរង របស់អគ្គលេខាធិការដ្ឋាននៃក្រុមប្រឹក្សាកំណែទំរង់រដ្ឋបាល បន្ថែមលើមុខងារបច្ចុប្បន្ន ។

**មាត្រា ២.-** ឲ្យនាយករដ្ឋមន្ត្រី ទេសរដ្ឋមន្ត្រី ទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការក្រសួងស្ថាប័នពាក់ព័ន្ធ អគ្គលេខាធិការដ្ឋាននៃក្រុមប្រឹក្សាកំណែទម្រង់រដ្ឋបាល និងសាមីខ្លួន ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះឲ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ១៤ ខែ មិនា ឆ្នាំ ២០០០

នាយករដ្ឋមន្ត្រី

ហត្ថលេខា និង ត្រា

ហ៊ុន សែន

★★★

## អនុក្រឹត្យលេខ ៩៦ អនក្រ .តត

## ស្ដីពីការបំពាក់ឋានន្តរសក្តិនាយនគរបាលជាតិ

***

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស / រកត / ១១៩៨ / ៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស / ៩៤ / ០២ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស / រកម / ០១៩៦ / ០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្ដីពីការបង្កើតក្រសួងមហាផ្ទៃ
- តាមសំណើរបស់សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## សំរេច

**មាត្រា ១.-** ត្រូវបានបំពាក់ឋានន្តរសក្តិថ្នាក់ **ឧត្តមសេនីយ៍ឯក** ជូននាយនគរបាលជាតិ ដូចមានរាយនាមខាងក្រោម :

១- លោក អ៊ុំ សំផុន អនុប្រធាននាយកដ្ឋានបុគ្គលិក

២- លោក កែវ វង្សា អនុប្រធាននាយកដ្ឋានសុខាភិបាល

មាត្រា ២.- រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ សហរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ និងសាមីខ្លួន ដូចមានចែងក្នុងមាត្រា ១ ត្រូវអនុវត្តអនុក្រឹត្យនេះ តាំងពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ១៥ ខែ មិនា ឆ្នាំ ២០០០
នាយករដ្ឋមន្ត្រី
បណ្ឌិតោ និង ត្រា
ហ៊ុន សែន

★★★

## អនុក្រឹត្យលេខ ៩៧ អនក្រ .តត
## ស្តីពីការបំពាក់ឋានន្តរសក្តិ
## នាយទាហាននៃកងយោធពលខេមរភូមិន្ទ

***

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ [illegible] ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស / រកម / ៩៤ / ០២ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស / រកម / ០១៩៦ / ០៧ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើត ក្រសួងការពារជាតិ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០១៩៩/២១ ចុះថ្ងៃទី ២៥ ខែ មករា ឆ្នាំ ១៩៩៩ ស្តីពីការកែសម្រួលតួនាទី ភារកិច្ច និងរចនាសម្ព័ន្ធចាត់តាំងអគ្គបញ្ជាការដ្ឋាន នៃកងយោធពលខេមរភូមិន្ទ
- យោងតាមសំណើរបស់សហរដ្ឋមន្ត្រី ក្រសួងការពារជាតិ

## សំរេច

មាត្រា ១.- ត្រូវបានតែងតាំង និងបំពាក់ ឋានន្តរសក្តិ នាយទាហានជាន់ខ្ពស់ ថ្នាក់ **ឧត្តមសេនីយ៍ឯក** ក្នុងកងយោធពលខេមរភូមិន្ទ ដូចមានរាយនាមដូចខាងក្រោម :

១- លោក ឌី ឆិន នាយសេនាធិការរង យោធភូមិភាគទី ១
២- លោក ខាន់ សឿន នាយសេនាធិការរង យោធភូមិភាគទី ២
៣- លោក នួន នៅ នាយសេនាធិការរង យោធភូមិភាគទី ៤
៤- លោកប៉ាំង នុត មេបញ្ជាការរង កងពលធំលេខ ១៥
៥- លោក នេម អយ មេបញ្ជាការរង កងពលធំលេខ ២៣
៦- លោក ជូ ជិន មេបញ្ជាការរង កងពលធំលេខ ២៣
៧- លោក អន ស៊ី មេបញ្ជាការរង កងពលធំលេខ ២៤
៨- លោក ទិទ សារ៉េន មេបញ្ជាការរង កងពលធំលេខ ២៤

មាត្រា ២.- រដ្ឋមន្ត្រីទទួលបន្ទុក ទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងការពារជាតិ រដ្ឋមន្ត្រី ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ រដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ អគ្គមេបញ្ជាការនៃកងយោធពលខេមរភូមិន្ទ សហរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួងស្ថាប័នពាក់ព័ន្ធនិងសាមីខ្លួន ដូចមានចែងក្នុងមាត្រា១ ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃ ចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ១៥ ខែ មីនា ឆ្នាំ ២០០០

នាយករដ្ឋមន្ត្រី

ហត្ថលេខា និង ត្រា

ហ៊ុន សែន

★★★

## អនុក្រឹត្យលេខ ៩៨ អនក្រ .តត
## ស្តីពីការជូនមេដាយស្ថាបនាជាតិ

***

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/រកម/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការប្រកាសប្រើគ្រឿងឥស្សរិយយសនៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់រដ្ឋមន្ត្រី ក្រសួងសុខាភិបាល

**សម្រេច**

មាត្រា ១.- ត្រូវបានប្រគល់ **មេដាយសេវិតថ្មីស្ថាបនាជាតិ** ជូនសម្បុរសជនខ្មែរនៅសហរដ្ឋអាមេរិក ០៥រូប ដែលបានធ្វើអំណោយជាគ្រែ ចំនួន ១១០គ្រែ ជូនមន្ទីរសុខាភិបាល ខេត្តពោធិសាត់ មានតំលៃជាប្រាក់ចំនួន ៨.២៥០ ដុល្លារអាមេរិក ដូចមានរាយនាមខាងក្រោមនេះ :

១- លោក **គឹមខា** អ្នកស្រី **ផាន់ សារឿម**

២- អ្នកស្រី **អ៊ុក អឿម**

៣- លោក **នួន ជេម** អ្នកស្រី **ឌុប លឿម**

៤- ឧបាសក **គេខ គុន** អ្នកស្រី **សយ**

៥- លោក **អ៊ូ មៃ** អ្នកស្រី **ម៉ែន ឌុច**

មាត្រា ២.- រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសុខាភិបាល និងអភិបាលខេត្តពោធិសាត់ ត្រូវអនុវត្តអនុក្រឹត្យនេះឲ្យទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ១៥ ខែ មីនា ឆ្នាំ ២០០០

នាយករដ្ឋមន្ត្រី

ហត្ថលេខា និង ត្រា

**ហ៊ុន សែន**

★★★

## អនុក្រឹត្យលេខ ៩៩ អនក្រ .តត

**ស្តីពីការផ្តល់មេដាយស្ថាបនាជាតិ**

***

**រាជរដ្ឋាភិបាល**

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/រកម/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការប្រកាសប្រើគ្រឿងឥស្សរិយយសនៃព្រះរាជាណាចក្រកម្ពុជា

- តាមសំណើរបស់ប្រតិភូរាជរដ្ឋាភិបាល ទទួលបន្ទុកអភិបាលរាជធានីភ្នំពេញ

**សំរេច**

**មាត្រា ១.-** ត្រូវបានប្រគល់ **មេដាយមាសស្ថាបនាជាតិ** ប្រគេនព្រះសង្ឃវត្តដៃចូ ធី ប្រទេសជប៉ុន ដែលបានឧបត្ថម្ភថវិកាជួយកសាងសង់អាគារសិក្សាមួយខ្នង នៅសាលាបឋមសិក្សា ស្ទឹងមានជ័យ អស់ថវិកាប្រាក់ចំនួន ១៧.៥០០ ដុល្លារអាមេរិក ។

**មាត្រា ២.-** រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី និងប្រតិភូរាជរដ្ឋាភិបាល ទទួលបន្ទុកអភិបាលរាជធានីភ្នំពេញ ត្រូវអនុវត្តអនុក្រឹត្យនេះឲ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ១៥ ខែ មីនា ឆ្នាំ ២០០០

នាយករដ្ឋមន្ត្រី

ហត្ថលេខា និង ត្រា

**ហ៊ុន សែន**

★★★

## អនុក្រឹត្យលេខ ១០០ អនក្រ .តត

## ស្ដីពីការជូនមេដាយស្ថាបនាជាតិ

***

**រាជរដ្ឋាភិបាល**

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/រកម/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្ដីពីការប្រគល់ការប្រើគ្រឿងឥស្សរិយយសនៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់អភិបាលខេត្តកំពង់ចាម

**សំរេច**

**មាត្រា ១.-** ត្រូវបានប្រគល់ **មេដាយមាសស្ថាបនាជាតិ** ជូនសមាគមកម្ពុជា-បូឡូញ ដែលបានជួយកសាងមណ្ឌលសុខភាពមួយខ្នង នៅភូមិដូនជុំ ឃុំសូទីប ស្រុកជើងព្រៃ ខេត្តកំពង់ចាម ចំណាយអស់ថវិកាចំនួន ៥៦.០០០ ដុល្លារអាមេរិក ។

មាត្រា ២.- រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និងអភិបាលខេត្តកំពង់ចាម ត្រូវអនុវត្តអនុក្រឹត្យនេះឲ្យទទួលបានផលតាមភារកិច្ចរៀងៗខ្លួន ។

រាជធានីភ្នំពេញ ថ្ងៃទី ១៥ ខែ មីនា ឆ្នាំ ២០០០

នាយករដ្ឋមន្ត្រី

ហត្ថលេខា និង ត្រា

**ហ៊ុន សែន**

★★★

## អនុក្រឹត្យលេខ ១០១ អនក្រ .តត

## ស្តីពីការជូនមេដាយស្ថាបនាជាតិ

***

### រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/រកម/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការប្រកាសប្រើគ្រឿងឥស្សរិយយសនៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើររបស់អភិបាលខេត្តកំពង់ចាម

### សំរេច

មាត្រា ១.- ត្រូវបានប្រគល់ **មេដាយស្ថាបនាជាតិ** ជូនសប្បុរសជនចំនួន ០៦រូប ដែលបានបរិច្ចាគថវិកា ផ្ទាល់ខ្លួនជួយកសាងសមិទ្ធផលផ្សេងៗ ដូចជា សាលារៀន ផ្លូវថ្នល់ វត្តអារាម ។ល។ នៅក្នុងស្រុកបាធាយ ខេត្តកំពង់ចាម ដូចមានរាយនាមខាងក្រោមនេះ :

**ក-មេដាយមាសស្ថាបនាជាតិ :**

១- ឯកឧត្តម **ហោ ណាំហុង** ទឹកប្រាក់ ចំនួន ៥០.០០០ដុល្លារអាមេរិក

២- លោកយាយ ដូនជី **ហ្សា គុយហ្សេ** ប្រទេសជប៉ុន ទឹកប្រាក់ ចំនួន ៣.៥០០.០០០យ៉េន

៣- លោក **ម៉ែន ដែន** ទឹកប្រាក់ ចំនួន ៥០.០០០ដុល្លារអាមេរិក

៤- លោក **យឹម សាំង** ទឹកប្រាក់ ចំនួន ១០.៥២៦ដុល្លារអាមេរិក

ខ-មេដាយសំរិទ្ធស្ថាបនាជាតិ :

១- លោក សំវ៉ាន់ស៊ី ទឹកប្រាក់ ចំនួន ៣.០០០ដុល្លារអាមេរិក

២- លោក អ៊ិន ឈាន ទឹកប្រាក់ ចំនួន ៣.០០០ដុល្លារអាមេរិក

មាត្រា ២.- រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និងអភិបាលខេត្តកំពង់ចាម ត្រូវអនុវត្តអនុក្រឹត្យនេះឲ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ១៥ ខែ មីនា ឆ្នាំ ២០០០

នាយករដ្ឋមន្ត្រី

ហត្ថលេខា និង ត្រា

ហ៊ុន សែន

★★★

## អនុក្រឹត្យលេខ ១០២ អនក្រ.តត

## ស្តីពីការជូនមេដាយស្ថាបនាជាតិ

***

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/រកម/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការប្រកាសប្រើគ្រឿងឥស្សរិយយសនៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់អភិបាលខេត្តកណ្តាល

## សំរេច

មាត្រា ១.- ត្រូវបានប្រគល់ មេដាយមាសស្ថាបនាជាតិ ប្រគេនព្រះតេជគុណ សោម ស៊ីម ព្រះគ្រូសូត្រស្តាំ វត្តព្រែកតាទ និងជាព្រះសង្ឃអនុគណ ស្រុកពញាឮ ខេត្តកណ្តាល ដែលបានបរិច្ចាគបច្ច័យចំនួន ៣៣.៥០០ដុល្លារអាមេរិក សំរាប់ជួសជុលផ្លូវលំម្ភូបខ្សែចម្ងាយ ១៣ គីឡូម៉ែត្រ ចាប់ពីព្រែកឡៅ ដល់ភ្នំប្រសិទ្ធិ ។

មាត្រា ២.- រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និងអភិបាលខេត្តកណ្តាល ត្រូវអនុវត្តអនុក្រឹត្យនេះឲ្យទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ១៥ ខែ មីនា ឆ្នាំ ២០០០

នាយករដ្ឋមន្ត្រី

ហត្ថលេខា និង ត្រា

ហ៊ុន សែន

★★★

## អនុក្រឹត្យលេខ ១០៣ អនក្រ.តត

## ស្តីពីការជូនមេដាយស្ថាបនាជាតិ

***

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការប្រកាសប្រើគ្រឿងឥស្សរិយយសនៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់អភិបាលខេត្តកណ្តាល

## សំរេច

មាត្រា ១.- ត្រូវបានប្រគល់ មេដាយមាសស្ថាបនាជាតិ ប្រគេនព្រះតេជព្រះគុណ ព្រះធម្មបាល ខេន ផាន ព្រះគ្រូសូត្រឆ្វេង វត្តច័ន្ទបុប្ផារង្សី ឃុំគោកគង ស្រុកពញាឮ ខេត្តកណ្តាល ដែលបានបរិច្ចាគបច្ច័យផ្ទាល់ព្រះអង្គ ជួយកសាងសមិទ្ធផលសាធារណៈនានា ក្នុងឃុំពញាពន់ និងឃុំឡើង ស្រុកពញាឮ ចំណាយអស់ថវិកាប្រាក់ សរុបចំនួន ៥៥.៩៦០ ដុល្លារអាមេរិក ។

មាត្រា ២.- រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និងអភិបាលខេត្តកណ្តាល ត្រូវអនុវត្តអនុក្រឹត្យនេះ ឲ្យមានប្រសិទ្ធភាពល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ១៥ ខែ មីនា ឆ្នាំ ២០០០

នាយករដ្ឋមន្ត្រី

បណ្ឌិតសភាចារ្យ និង ត្រា

ហ៊ុន សែន

★★★

## អនុក្រឹត្យលេខ ១០៤ អនក្រ.តត

## ស្តីពីការផ្តល់មេដាយស្ថាបនាជាតិ

***

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/រកម/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការប្រកាសប្រើគ្រឿងឥស្សរិយយសនៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់អភិបាលខេត្តកណ្តាល

## សម្រេច

មាត្រា ១.- ត្រូវបានប្រគល់ មេដាយស្ថាបនាជាតិ តាមលំដាប់ថ្នាក់ ប្រពេន និងជូនគប្បុរសជនចំនួន ០៨ រូប ដែលបានបរិច្ចាគថវិកាជួយកសាងសមិទ្ធផលផ្សេងៗ នៅក្នុងវត្តមហាខេត្តវ័ន ឃុំជើងកើប ស្រុកកណ្តាលស្ទឹង ខេត្តកណ្តាល ដូចជាព្រះវិហារ កុដិព្រះសង្ឃ សាលាឆាន់ ។ល។ ដូចមានរាយព្រះនាម និងនាមខាងក្រោមនេះ :

**ក-មេដាយមាសស្ថាបនាជាតិ :**

- ព្រះតេជគុណ ទី ឡើង ព្រះចៅអធិការវត្តមហាខេត្តវ័ន បច្ច័យចំនួន ១១.៣១០ USD

**ខ-មេដាយប្រាក់ស្ថាបនាជាតិ :**

១- លោក នុត សាឡើន ជនជាតិខ្មែរ នៅសហរដ្ឋអាមេរិក ទឹកប្រាក់ចំនួន ៧.២២៦ USD

២- លោក ម៉ូរ ណារ៉េត អភិបាលស្រុកកណ្តាលស្ទឹងស្តីទី ទឹកប្រាក់ចំនួន ៥.៣០០ USD

គ-មេដាយសំរិទ្ធស្ថាបនាជាតិ :

| | | |
|---|---|---|
| ១- លោកវេជ្ជ. ចៅ គីមឿន និងភរិយា | ទឹកប្រាក់ចំនួន | ៣.៥៩៧ USD |
| ២- ឧបាសិកា សំប៉ាន់ | ទឹកប្រាក់ចំនួន | ៣.៥៨៣ USD |
| ៣- លោក លៀង ហេង និងភរិយា | ទឹកប្រាក់ចំនួន | ២.៥០០ USD |
| ៤- លោកតាន់ ផាត ប្រធានគណៈកម្មការវត្តអបរាជេត្តវ័ន | ទឹកប្រាក់ចំនួន | ១.៥០០ USD |
| ៥- លោក ធី និងភរិយា ជនជាតិខ្មែរ នៅសហរដ្ឋអាមេរិក | ទឹកប្រាក់ចំនួន | ១.០០០ USD |

**មាត្រា ២.-** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និងអភិបាលខេត្តកណ្តាល ត្រូវអនុវត្តអនុក្រឹត្យនេះឲ្យទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ១៥ ខែ មិនា ឆ្នាំ ២០០០

នាយករដ្ឋមន្ត្រី

ហត្ថលេខា និងត្រា

**ហ៊ុន សែន**

★★★

## អនុក្រឹត្យលេខ ១០៥ អនក្រ.តត

## ស្តីពីការជូនមេដាយស្ថាបនាជាតិ

***

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការប្រកាសឲ្យប្រើគ្រឿងឥស្សរិយយសនៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់អភិបាលខេត្តកណ្តាល

## សំរេច

**មាត្រា ១.-** ត្រូវបានប្រគល់ មេដាយស្ថាបនាជាតិ តាមលំដាប់ថ្នាក់ប្រគេននិងជូនសប្បុរសជនដែលបានបរិច្ចាគថវិកាជួយកសាងព្រះវិហារវត្តកោះអណ្តែត ក្នុងឃុំព្រែកម្កាក់ ស្រុកអង្គស្នួល ខេត្តកណ្តាល ដូចមានរាយព្រះនាម និងនាមខាងក្រោមនេះ :

**ក-មេដាយមាសស្ថាបនាជាតិ :**

១- ព្រះតេជគុណ **ជិន ឡូត** ព្រះចៅអធិការវត្តកោះអំពៅត បច្ច័យចំនួន ៣៨.១៥៥ USD

២- លោក **គន់ មូហោ** ជនជាតិខ្មែរ រស់នៅប្រទេស ញូសេឡេន ទឹកប្រាក់ចំនួន ១១.០៥០ USD

**ខ-មេដាយប្រាក់ស្ថាបនាជាតិ :**

១- លោក **សៀង រីម** ទឹកប្រាក់ចំនួន ៦.០០០ USD

២- លោក **គន់ ជា** ទឹកប្រាក់ចំនួន ៦.០០០ USD

៣- លោក **សរ ឡេង** ទឹកប្រាក់ចំនួន ៦.០០០ USD

មាត្រា ២.- រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និងអភិបាលខេត្តកណ្តាល ត្រូវអនុវត្តអនុក្រឹត្យនេះ ឲ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ១៥ ខែ មីនា ឆ្នាំ ២០០០

នាយករដ្ឋមន្ត្រី

ហត្ថលេខា និង ត្រា

**ហ៊ុន សែន**

★★★

# **អនុក្រឹត្យលេខ ១០៦ អនក្រ .តត**

## **ស្តីពីការជូនមេដាយស្ថាបនាជាតិ**

***

## **រាជរដ្ឋាភិបាល**

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/រកម/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការ
- ប្រកាសប្រើគ្រឿងឥស្សរិយយសនៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងអប់រំ យុវជននិងកីឡា

## **សំរេច**

មាត្រា ១.- ត្រូវបានប្រគល់ **មេដាយមាសស្ថាបនាជាតិ** ជូនលោកស្រី **ម៉ារីកូ អូកាម៉ូតូ** ប្រធានអង្គការ ASAC ជប៉ុន ដែលបានជួយកសាងអាគារសិក្សា ០២ខ្នង និងជួសជុល ០១ខ្នង នៅសាលាបឋមសិក្សា សំបួរអាស" មិត្តភាព

កម្ពុជា-ជប៉ុន" ក្នុងភូមិពាមជីកង ស្រុកកងមាស ខេត្តកំពង់ចាម ចំណាយអស់ថវិកាសរុបចំនួន ៨៥.០០០ ដុល្លារអាមេរិក ។

មាត្រា ២.- រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា និងអភិបាលខេត្តកំពង់ចាម ត្រូវអនុវត្តអនុក្រឹត្យនេះ ឲ្យទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ១៥ ខែ មីនា ឆ្នាំ ២០០០

នាយករដ្ឋមន្ត្រី

ហត្ថលេខា និង ត្រា

ហ៊ុន សែន

★★★

## ២- សេចក្តីសំរេច

Phnom Penh , March 09 , 2000

**Decision No :15 D**

## The appointment of an Advisor to the Prime Minister of the Kingdom of Cambodia

***

### The Royal Government

- Seen the constitution of the Kingdom of Cambodia
- Seen the Royal Decree No NS/RKT/1198/72 dated November 30 1998 on the appointment of the Royal Government of the Kingdom of Cambodia
- Seen the Reachkrom No 02/NS/94 dated July 20,1994 which promulgated the law on the organization and functioning of the Council of Ministers
- Pursuant to the needs of the Royal Government of Cambodia

Hereby Decides :

Article 1 : To appoint Mr. LEE MYUNG BAK as an Advisor to Samdech Hun Sen, Prime Minister of the Royal Government of Cambodia.

Article 2 : Mr. LEE MYUNG BAK has to implement this decision from the date of its signature.

Prime Minister

Hun Sen

***

រាជធានីភ្នំពេញ ថ្ងៃទី ១៤ ខែ មីនា ឆ្នាំ ២០០០

## សេចក្ដីសម្រេចលេខ ១៦ សសរ.

## ស្ដីពីរូបសញ្ញា ក្រសួងការពារជាតិ

***

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រម នស/រកម/០១៩៦/០៧ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ប្រកាសឲ្យប្រើច្បាប់ស្ដីពីការបង្កើត ក្រសួងការពារជាតិ
- បានឃើញព្រះរាជក្រឹត្យលេខ ៣៧/អនក្រ/បក ចុះថ្ងៃទី ១៦ ខែ កុម្ភៈ ឆ្នាំ ១៩៩៩ ស្ដីពីការកែសម្រួលរចនាសម្ព័ន្ធចាត់តាំង ក្រសួងការពារជាតិ
- យោងតាមសំណើរបស់សហរដ្ឋមន្ត្រី ក្រសួងការពារជាតិ

## សម្រេច

**ប្រការ ១ :** កំណត់រូបសញ្ញា និងនិយមន័យ នៃរូបសញ្ញារបស់ក្រសួងការពារជាតិដូចខាងក្រោម :

រូបសញ្ញារបស់ក្រសួងការពារជាតិ ត្រូវតំណាងដោយរង្វង់មូល នៅកណ្ដាលរង្វង់មូលមានរូបហនុមានទ្រង់គ្រឿង ផ្នែកខាងក្រោមរង្វង់មូលមានចរឹកអក្សរថា" ក្រសួងការពារជាតិ" លើរង្វង់មូលមានមកុដលើមកុដមានពន្លឺធព្វណ្ណរង្សី ខាងក្រោមរង្វង់មូលទ្រដោយយុថ្កា មានសញ្ញាស្លាបសន្ទឹងសងខាងរង្វង់ និងអមដោយកួរស្រូវព័ទ្ធជុំវិញរង្វង់ ។

- ពន្លឺធព្វណ្ណរង្សី តំណាងឲ្យទសពិធរាជធម៌ នៃអង្គព្រះមហាក្សត្រ ។
- រូបមកុដទ្រង់គ្រឿង តំណាងឲ្យជាតិ សាសនា ព្រះមហាក្សត្រ ។
- ក្បាច់ រំលេចលតំណាងឲ្យការរក្សានូវប្រពៃណី និងខឿនវប្បធម៌ជាតិ ។
- ផ្ការង្វង់ពណ៌ក្រហមភ្ជាប់ និងរំយោលសងខាងបញ្ជាក់ឲ្យឈ្មោះស្ថាប័នរបស់ក្រសួងការពារជាតិ ។
- រូបហនុមានទ្រង់គ្រឿង ដែលស្ពាយក្ដាក់ចង្គូលធ្លោះត្រង់ទៅមុខ ដៃឆ្វេងកាន់ព្រះខ័នសំដែងឫទ្ធិតំណាងឲ្យកងយោធពលខេមរភូមិន្ទ ជាមេទ័ព និងពលសេនាទ័ពជើងគោកដ៏មានឫទ្ធិ មានទឹកចិត្តភក្ដីភាពចំពោះមាតុភូមិ ការពារជាតិ សាសនា និងព្រះមហាក្សត្រ ។

- រូបសញ្ញាស្លាបសន្ទឹងសងខាង តំណាងឲ្យកងទ័ពជើងអាកាស និងយុថ្កាតំណាងឲ្យកងទ័ពជើងទឹក ដែលប្រសូត្រចេញពីប្រជាជន ហ៊ានធ្វើពលិកម្ម ពុះពារជំនះគ្រប់ឧបសគ្គតូច-ធំមានឆន្ទៈមោះមុត ដើម្បីការពារឧត្តមប្រយោជន៍ជាតិ អធិបតេយ្យភាព និងបូរណភាពទឹកដី ដែនគោក ដែនទឹក ដែនកោះ និងដែនអាកាស រក្សាឲ្យភាពសុខដុមរម្យនារបស់ប្រជាពលរដ្ឋក្នុងព្រះរាជាណាចក្រកម្ពុជាទាំងមូល ។
- កួរស្រូវអមសងខាងព័ទ្ធជារង្វង់ បញ្ជាក់ការរួមចំណែកការបង្កបង្កើនផលក្នុងកិច្ចអភិវឌ្ឍន៍ប្រទេសជាតិ មានស្រូវជាដំណាំកសិកម្មដ៏សំខាន់ ដែលកងទ័ពយកចិត្តទុកដាក់បំផុតស្របនឹងពាក្យស្លោកថែងថា : "ធ្វើស្រែនឹងទឹក ធ្វើសឹកនឹងបាយ" ។

ប្រការ ២ : រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងការពារជាតិ សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង-ស្ថាប័ន អភិបាលគ្រប់ខេត្ត-ក្រុង ត្រូវអនុវត្តសេចក្ដីសំរេចនេះ ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

នាយករដ្ឋមន្ត្រី

ហត្ថលេខា និង ត្រា

ហ៊ុន សែន

***

# III- ការងារបណ្ដាក្រសួង

## ១-ទីស្ដីការគណៈរដ្ឋមន្ត្រី

## សេចក្ដីសំរេច

រាជធានីភ្នំពេញ ថ្ងៃទី ១៣ ខែ មីនា ឆ្នាំ ២០០០

**សេចក្ដីសំរេចលេខ ២០ សសរ.**

**ស្ដីពីការចាត់តាំងភារកិច្ចមន្ត្រីមធ្យម**

**ជំនាន់សន្និធាត ២**

***

**ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤៩៥/៤០ ចុះថ្ងៃទី ២១ ខែ មេសា ឆ្នាំ ១៩៩៥ ស្ដីពីការបង្កើតសាលាភូមិន្ទរដ្ឋបាល

- បានឃើញអនុក្រឹត្យលេខ ៨០ អនក្រ ចុះថ្ងៃទី ០៥ ខែ ធ្នូ ឆ្នាំ ១៩៩៥ ស្តីពីលក្ខន្តិកៈរបស់សាលាភូមិន្ទរដ្ឋបាល
- បានឃើញសេចក្តីសំរេចលេខ ០៨ សសរ. ចុះថ្ងៃទី ១២ ខែ សីហា ឆ្នាំ ១៩៩៦ របស់ទីស្តីការគណៈរដ្ឋមន្ត្រី ស្តីពីការប្រឡងជ្រើសរើសមន្ត្រីមធ្យម
- យោងតាមសេចក្តីត្រូវការជាក់ស្តែង នៅឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម

**សំរេច**

**ប្រការ ១ :** មន្ត្រីមធ្យមជំនាន់" សន្តិភាព២" ចំនួន ០២នាក់ ដូចមានរាយនាមខាងក្រោម ត្រូវចាត់ឲ្យបំរើការងារនៅឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម :

១- លោក **សម ម៉ិនថុន**

២- លោក **សំ ប្រជាមានិត**

**ប្រការ ២ :** មន្ត្រីមានអតីតភាពជាសិស្ស ត្រូវធ្វើកម្មសិក្សារយៈពេល១២ខែ និងធ្វើកម្មសិក្សារយៈពេល៦ខែ អ្នកដែលមានអតីតភាពជាមន្ត្រី ។ ចំពោះអ្នកដែលទៅអង្គភាពដើម មិនត្រូវបានធ្វើកម្មសិក្សា ។

**ប្រការ ៣ :** ក្រុមប្រឹក្សាភិបាលសាលាភូមិន្ទរដ្ឋបាល សាលាភូមិន្ទរដ្ឋបាល នាយកដ្ឋានរដ្ឋបាល-បុគ្គលិក នាយកដ្ឋានផ្គត់ផ្គង់ និងហិរញ្ញកិច្ច ព្រមទាំងសាមីខ្លួនមានភារកិច្ចអនុវត្តសេចក្តីសំរេចនេះ ឲ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ទេសរដ្ឋមន្ត្រី
ហត្ថលេខា និង ត្រា
**សុខ អាន**

★★★

រាជធានីភ្នំពេញ ថ្ងៃទី ១៣ ខែ មីនា ឆ្នាំ ២០០០

## សេចក្តីសំរេចលេខ ២១ សសរ.
## ស្តីពីការជ្រើសរើសកន្លែងបំពេញមុខងារ
## របស់សិស្សមន្ត្រីមធ្យម ជំនាន់សន្តិភាព ២

***

## ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា

- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤៩៥/៤០ ចុះថ្ងៃទី ២១ ខែ មេសា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើតសាលាភូមិន្ទរដ្ឋបាល
- បានឃើញអនុក្រឹត្យលេខ ៤០ អនក្រ ចុះថ្ងៃទី ០៥ ខែ ឧសភា ឆ្នាំ ១៩៩៥ ស្តីពីលក្ខន្តិកៈរបស់សាលាភូមិន្ទរដ្ឋបាល
- បានឃើញសេចក្តីសម្រេចលេខ ០៨ សសរ. ចុះថ្ងៃទី ១២ ខែ សីហា ឆ្នាំ ១៩៩៦ របស់ទីស្តីការគណៈរដ្ឋមន្ត្រី ស្តីពីការប្រឡងជ្រើសរើសមន្ត្រីមធ្យម
- បានឃើញលិខិតលេខ ១៥៩២ សជណ សករ ចុះថ្ងៃទី ០៣ ខែ វិច្ឆិកា ឆ្នាំ ១៩៩៩ របស់ទីស្តីការគណៈរដ្ឋមន្ត្រី ស្តីពីការណើសិស្សមន្ត្រីមធ្យមលើកទី ២ និងសិស្សមន្ត្រីជាន់ខ្ពស់លើកទី ១
- យោងតាមលិខិតឆ្លើយតបរបស់ក្រសួងនានា

**សំរេច**

ប្រការ ១ : កន្លែងបំពេញមុខងារមានចំនួន ៤៦ កន្លែង ត្រូវបានបែងចែក ដូចខាងក្រោម :

| | |
|---|---|
| ១- ក្រសួងមហាផ្ទៃ | ៣០ កន្លែង |
| ២- ក្រសួងសាធារណការ និងដឹកជញ្ជូន | ០១ កន្លែង |
| ៣- ក្រសួងធនធានទឹក និងឧតុនិយម | ០២ កន្លែង |
| ៤- ក្រសួងបរិស្ថាន | ០៣ កន្លែង |
| ៥- ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ | ១០ កន្លែង |

ប្រការ ២ : ការជ្រើសរើសកន្លែងត្រូវធ្វើតាមចំណាត់ថ្នាក់បញ្ចប់នៃការសិក្សារយៈពេល២ឆ្នាំ របស់សិស្សស្របតាមលក្ខន្តិកៈរបស់សាលាភូមិន្ទរដ្ឋបាល អ្នកមានចំណាត់ថ្នាក់ល្អមានអាទិភាពជ្រើសរើសមុន ។

ប្រការ ៣ : សាលាភូមិន្ទរដ្ឋបាល នាយកដ្ឋានផ្គត់ផ្គង់ និងហិរញ្ញកិច្ច នាយកដ្ឋានរដ្ឋបាល-បុគ្គលិក មានភារកិច្ចអនុវត្តសេចក្តីសំរេចនេះ ឲ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

ទេសរដ្ឋមន្ត្រី

ហត្ថលេខា និង ត្រា

**សុខ អាន**

★★★

## ២-ទីស្ដីការរដ្ឋមន្ត្រី ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល

### ប្រកាស

រាជធានីភ្នំពេញ ថ្ងៃទី ១៣ ខែ មីនា ឆ្នាំ ២០០០

**ប្រកាសលេខ ១៥១ កឧ.ប្រក**

***

**រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល**

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ លេខ នស / រកត / ១១៩៨ / ៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ របស់ព្រះករុណាព្រះបាទសម្ដេចនរោត្តមសីហនុវរ្ម័ន ព្រះចៅក្រុងកម្ពុជាធិបតី ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៥ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្ដីពីការបង្កើត ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល
- បានឃើញអនុក្រឹត្យលេខ ៣៥ អនក្រ.បក ចុះថ្ងៃទី ២៦ ខែ មេសា ឆ្នាំ ១៩៩៩ របស់រាជរដ្ឋាភិបាលកម្ពុជា ស្ដីពីការរៀបចំនិងការប្រព្រឹត្តិទៅរបស់ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល
- បានឃើញលិខិតលេខ ១៥២២/៩៨ គ.វ.ក ចុះថ្ងៃទី ០១-០៩-១៩៩៨ របស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- បានឃើញលិខិតលេខ ១៦៥ ប.ស្ថ.សាណ ចុះថ្ងៃទី ២៩-០២-២០០០ របស់ក្រសួងបរិស្ថាន
- បានឃើញលិខិតលេខ ៣០៤ លក.កសន ចុះថ្ងៃទី ១៤-០៥-១៩៩៩ របស់សាលាក្រុងព្រះសីហនុ
- យោងពាក្យស្នើរបស់ក្រុមហ៊ុន ភ្នំពេញ ធើរប៊ែកខូ (ខេមបូឌា) ចុះថ្ងៃទី ១១-០២-២០០០

**សំរេច**

**ប្រការ ១ :** អនុញ្ញាតឲ្យក្រុមហ៊ុន ភ្នំពេញ ធើរប៊ែកខូ (ខេមបូឌា) PHNOM PENH TOBACCO (CAMBODIA) តំណាងដោយលោក វិញ ហ៊ួរ សញ្ញាតិកម្ពុជា ភេទប្រុស អាយុ៥៦ឆ្នាំ កាន់អត្តសញ្ញាណប័ណ្ណលេខ ៣២៥៩២៧ ភព ចុះថ្ងៃទី ១០-១២-១៩៩១ បង្កើតរោងចក្រផលិតបារីសំរាប់នាំចេញ ដែលមានផ្លាកឈ្មោះថា "រោងចក្រផលិតបារីភ្នំពេញ" មានទីតាំងស្ថិតនៅ ភូមិមណ្ឌល១ សង្កាត់លេខ ១ ខណ្ឌមិត្តភាព ក្រុងព្រះសីហនុ ។

**ប្រការ ២ :** ការរៀបចំអាគារនិងគ្រឿងចក្រ ក្រុមហ៊ុនត្រូវធ្វើទៅតាមប្លង់ដែលបានតំកល់ទុកនៅក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ឲ្យបានសំរេចក្នុងរយៈពេល ០៦ខែ ដោយរាប់បញ្ចូលទាំងរយៈពេលដំណើរការសាកល្បង ។

ប្រការ ៣ : រោងចក្រនេះត្រូវបានអនុញ្ញាតឲ្យផលិត "បារីតញ្ចប់ទន់ និងកញ្ចប់រឹង" ទៅតាមគំរូនិងសញ្ញាសំគាល់ដែលបានតម្កល់ទុកហើយត្រូវធ្វើរបាយការណ៍ប្រចាំខែ អំពីស្ថានភាពផលិតកម្មរបស់រោងចក្រ ជូនក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ។

ប្រការ ៤ : ក្រុមហ៊ុនត្រូវលើកបង្ហាញ "ផ្លាកឈ្មោះរោងចក្រ" របស់ខ្លួនជាអក្សរខ្មែរមានទំហំធំជាង និងនៅពីលើអក្សរផ្សេងទៀត នៅកន្លែងដែលងាយមើលឃើញនៅខាងមុខរោងចក្រ ។

ប្រការ ៥ : ក្រុមហ៊ុនត្រូវធានាសុវត្ថិភាពឧស្សាហកម្ម គុណភាពផលិតផល អនាម័យក្នុងរោងចក្រ ព្រមទាំងត្រូវគោរពឲ្យបានម៉ឺងម៉ាត់ នូវច្បាប់ស្តីពីការងារ ច្បាប់ស្តីពីកិច្ចការពារបរិស្ថាននិងការគ្រប់គ្រងធនធានធម្មជាតិ និងច្បាប់បទប្បញ្ញត្តិនានា ដែលពាក់ព័ន្ធនឹងផលិតកម្ម អាជីវកម្មរបស់ក្រុមហ៊ុន ។

ប្រការ ៦ : ក្នុងករណីប្រព្រឹត្តិល្មើសច្បាប់ ឬល្មើសធ្ងន់ធ្ងរនឹងប្រការណាមួយដែលបានចែងខាងលើ ប្រកាសនេះនឹងត្រូវដកហូតវិញដោយគ្មានសំណងឡើយ ។

ប្រការ ៧ : អគ្គនាយកឧស្សាហកម្ម នៃក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ប្រធានមន្ទីរឧស្សាហកម្ម រ៉ែ និង ថាមពល ក្រុងព្រះសីហនុ និង ប្រធានក្រុមហ៊ុន ភ្នំពេញ ឆើរបែកខូ (ខេមបូឌា) ខូ អិលធីឌី ត្រូវអនុវត្តប្រកាសនេះតាមមុខការរៀងៗខ្លួន ។

ប្រការ ៨ : ប្រកាសនេះ មានអនុភាពអនុវត្ត ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រដ្ឋមន្ត្រី

ហត្ថលេខា និង ត្រា

ស៊ុយ សែម

★★★

## ៣-ទីស្តីការរដ្ឋមន្ត្រី ក្រសួងអប់រំ យុវជន និងកីឡា

## ប្រកាស

រាជធានីភ្នំពេញ ថ្ងៃទី ១៥ ខែ មីនា ឆ្នាំ ២០០០

### ប្រកាសលេខ ៥៦៩ អយក.ប្រក

### ស្តីពីការបើក អនុវិទ្យាល័យ ទួលក្បៀល ក្នុង ឃុំ កំពង់ស្វាយ ស្រុក កំពង់ស្វាយ ខេត្ត កំពង់ធំ

***

### រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និង កីឡា

- បានឃើញព្រះរាជក្រឹត្យ លេខ នស.រកត ១១៩៨-៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម លេខ ០២ នស-៩៤ ចុះថ្ងៃទី ២០ កក្កដា ១៩៩៤ ស្តីពីការរៀបចំ និងប្រព្រឹត្តិទៅ នៃគណៈរដ្ឋមន្ត្រី

- បានឃើញព្រះរាជក្រម នស-រកម ០១៩៦-០១ ចុះថ្ងៃទី ២៤ មករា ១៩៩៦ ស្តីពីការបង្កើតក្រសួងអប់រំ យុវជន និង កីឡា
- បានឃើញព្រះរាជក្រឹត្យ លេខ នស-រកត ០៧៩៦-៥២ ចុះថ្ងៃទី ២៦ កក្កដា ១៩៩៦ ស្តីពីប្រព័ន្ធអប់រំចំនេះទូទៅ ១២ឆ្នាំ
- បានឃើញអនុក្រឹត្យលេខ ២១ អនក្រ -បក ចុះថ្ងៃទី ២៣ មីនា ១៩៩៨ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅរបស់ក្រសួងអប់រំ យុវជន និងកីឡា
- បានឃើញសារាចរណែនាំលេខ ៦៦ អរ.ចទម ចុះថ្ងៃទី ០២ មេសា ១៩៨៣ ស្តីពីការបើកសាលារៀនមធ្យមសិក្សាកំរិត១-កំរិត២
- យោងលិខិតស្នើសុំរបស់ សហគមន៍ ឃុំកំពង់ស្វាយ ចុះថ្ងៃទី ៣១ ខែ ឧសភា ១៩៩៩ ដោយមានយោបល់ឯកភាពពីមន្ទីរអប់រំ យុវជន និង កីឡា និង អភិបាលខេត្ត កំពង់ធំ
- តាមយោបល់ឯកភាពរបស់នាយកដ្ឋានមធ្យមសិក្សាចំនេះទូទៅ

**សំរេច**

**ប្រការ ១ :** អនុញ្ញាតឲ្យបើកអនុវិទ្យាល័យដែលមានឈ្មោះថា អនុវិទ្យាល័យ ទួលក្រឡិល ចាប់ពីឆ្នាំសិក្សា ១៩៩៩-២០០០ តទៅ ។

**ប្រការ ២ :** អនុវិទ្យាល័យនេះត្រូវដឹកនាំដោយនាយកមួយរូប និងនាយករងតាមការចាំបាច់ ព្រមទាំងបុគ្គលិកផ្សេងៗ ប្អូយចំនួនទៀតតាមអង្គការលេខ នៃអនុវិទ្យាល័យ ។

**ប្រការ ៣ :** នាយក-នាយករងនៃអនុវិទ្យាល័យមានសិទ្ធិទទួលប្រាក់បំណាច់ភារកិច្ចតាមគោលការណ៍របស់រដ្ឋ ។

**ប្រការ ៤ :** អគ្គនាយករដ្ឋបាល និង ហិរញ្ញវត្ថុ អគ្គនាយកអប់រំ ប្រធាននាយកដ្ឋានមធ្យមសិក្សាចំនេះទូទៅ ប្រធាននាយកដ្ឋានបុគ្គលិក ប្រធាននាយកដ្ឋានផែនការ និង ប្រធាននាយកដ្ឋានហិរញ្ញវត្ថុ នៃក្រសួងអប់រំ យុវជន និងកីឡាខេត្តកំពង់ធំ និងនាយកអនុវិទ្យាល័យសាមី មានភារកិច្ចរៀងខ្លួនៗ អនុវត្តប្រកាសនេះ ។

រដ្ឋលេខាធិការ

ហត្ថលេខា និង ត្រា

**អ៊ឹម សិទ្ធី**

★★★

# ៩-ទីស្តីការរដ្ឋមន្ត្រី ក្រសួងប្រៃសណីយ៍ និង ទូរគមនាគមន៍

## ប្រកាស

រាជធានីភ្នំពេញ ថ្ងៃទី ១០ ខែ មីនា ឆ្នាំ ២០០០

**ប្រកាសលេខ ០៨៦ បឧ.ប្រក**

**ស្តីពីការ បង្កើតការិយាល័យវិទ្យុឆ្នេរសមុទ្រ**

***

**រដ្ឋមន្ត្រីក្រសួងប្រៃសណីយ៍ និង ទូរគមនាគមន៍**

- បានឃើញរដ្ឋធម្មនុញ្ញ នៃ ព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស / រកត / ១១៩៨ / ៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ / នស / ៩៤ ចុះថ្ងៃទី ២០ កក្កដា ១៩៩៤ ស្តីពីការរៀបចំ និង ប្រព្រឹត្តិទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស / រកម / ០១៩៦ / ២០ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងប្រៃសណីយ៍ និង ទូរគមនាគមន៍
- បានឃើញអនុក្រឹត្យលេខ ៦៦ / អនក្រ / បកចុះថ្ងៃទី ២២ ខែ តុលា ឆ្នាំ ១៩៩៧ ស្តីពីការរៀបចំ និង ការប្រព្រឹត្តិទៅរបស់ក្រសួងប្រៃសណីយ៍ និង ទូរគមនាគមន៍
- យោងតាមស្មារតីអង្គប្រជុំថ្នាក់ដឹកនាំក្រសួង ចុះថ្ងៃទី ២៩-០២-២០០០
- បានឃើញការងារចាំបាច់របស់ក្រសួង

**សំរេច**

**ប្រការ ១ :** ត្រូវបានបង្កើត ការិយាល័យវិទ្យុឆ្នេរសមុទ្រ ដែលមានទីតាំងនៅក្រុងព្រះសីហនុ ស្ថិតនៅក្រោមការគ្រប់គ្រងផ្ទាល់ របស់ នាយកដ្ឋានទូរគមនាគមន៍អន្តរជាតិ ។

**ប្រការ ២ :** ខុទ្ទកាល័យ -អធិការដ្ឋាន-គ្រប់នាយកដ្ឋានក្រោមឱវាទក្រសួង ត្រូវទទួលបន្ទុកអនុវត្តន៍តាមខ្លឹមសារនៃប្រកាសនេះ ។

ប្រការ ៣ : រាល់ប្រកាសទាំងឡាយណាដែលផ្ទុយពីខ្លឹមសារ នៃប្រកាសនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

ប្រការ ៤ : ប្រកាសនេះមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រដ្ឋមន្ត្រី

ហត្ថលេខា និង ត្រា

សុ យុន